## វត្ថុសំខាន់ៗខ្លះ ដែលលោកអ្នកគួរចងចាំ :

1. អ្នកទទួលខុសត្រូវសង្គមមិនអាចមានសិទ្ធិផ្តល់ឲ្យឱវាទពីច្បាប់ទម្លាប់ប្រាប់ដល់លោកអ្នកឡើយ ប៉ុន្តែអាចពន្យល់ពីរបៀប។



2. បើសិនជាលោកអ្នកមានសំណួរអ្វីៗទៀតអំពីរបៀបបែបបទ សូមសាកសួរទៅមេធាវី ឬចៅក្រម។

3. លោកអ្នកត្រូវតែបញ្ជាក់ប្រាប់តុលាការនិងអ្នកទទួលខុសត្រូវសង្គមពីទីកន្លែងគេអាចផ្ញើសំបុត្រឲ្យលោកអ្នកបានធ្វើដូច្នេះ លោកអ្នកមិនបាត់សំបុត្រឯកសារសំខាន់ៗទាក់ទងនិងរឿងរ៉ាវកូនលោកអ្នកឡើយ។ បើសិនជាលោកអ្នកបានផ្លាស់ប្តូរអាសយដ្ឋានលោកអ្នកត្រូវតែប្រាប់មកអ្នកទទួលខុសត្រូវសង្គមភ្លាម។

## ពត៌មានបន្ថែម :

លេខទូរស័ព្ទសំខាន់ៗខ្លះ :

អ្នកទទួលខុសត្រូវសង្គម : ____________________

តុលាការសម្រាប់ក្មេង : ____________________

មេធាវី : ____________________



ខែថ្ងៃឆ្នាំសវនាការខ្ញុំលើកក្រោយ គឺ :

________________________________________



# ____________ ខោនធី
# តុលាការសម្រាប់ក្មេង

# តុលាការពឹងផ្អែក : របៀបតុលាការដើរ



Form Approved for Optional Use
Judicial Council of California
JV–055 CM (Cambodian) [Rev. January 1, 2001]



គោលដៅមួយរបស់តុលាការពឹងផ្អែក គឺរកវិធីដោះស្រាយ បញ្ហាកូនលោកអ្នកឲ្យបានឆាប់រហ័សដែលអាចធ្វើទៅរួច។ យើងត្រូវការជំនួយ ហើយនិងសហការពីលោកអ្នកដើម្បី ប្រព្រឹត្តធ្វើតាម។ តុលាការបានក្លាយចូលរួមជាមួយលោកអ្នក ហើយនិងកូនលោកអ្នក ពីព្រោះតែមានបុព្វហេតុខ្លះបានកើតឡើងក្នុងឆាកជីវិតរបស់លោកអ្នក ដែលនាំឲ្យមានការចូលរួមនេះ; គេនឹងតម្រូវឲ្យលោកអ្នកប្រព្រឹត្តធ្វើតាមបែបបទជាក់លាក់ខ្លះ ដើម្បីបញ្ចាក់ពីការចូលរួមរបស់តុលាការក្នុងរឿងនេះ។ លោកអ្នកត្រូវធ្វើតាមបែបបទនេះក្នុងកំឡុងរយៈពេលមានកំរិតច្បាស់លាស់ណាមួយ។ បែបបទនិងរយៈពេលវេលានឹងមានពន្យល់ដល់លោកអ្នក។

បើសិនជាកូនលោកអ្នកបានក្លាយទៅជាបន្ទុករបស់តុលាការនោះ មានន័យថាតុលាការចេញបទបញ្ជាឲ្យលោកអ្នក, កូនលោកអ្នក ហើយនិងអ្នកទទួលខុសត្រូវសង្គមធ្វើដូច្នេះ គឺមានការថែទាំការពារដល់កូនលោកអ្នកបាន។ នៅក្នុងករណីជាច្រើនលោកអ្នកអាចមានឱកាសបញ្ចប់ការចូលរួមរបស់តុលាការបាន។

ក្នុងបន្ទុករបស់តុលាការ :

1. តុលាការប្រហែលជាអនុញ្ញាតឲ្យកូននេះមករស់នៅក្នុងផ្ទះជាមួយលោកអ្នកក្រោមការមើលខុសត្រូវរបស់តុលាការ; ឬ
2. តុលាការប្រហែលជាដាក់កូនលោកអ្នកឲ្យរស់នៅកន្លែងផ្សេងទៀត។

បើសិនជានៅក្នុងរយៈពេលដែលកូនលោកអ្នកនៅក្នុងបន្ទុករបស់តុលាការ, ការជួបជុំក្រុមគ្រួសារឡើងវិញ គឺគ្មានបញ្ហាឲ្យមានទេ, ឬ ការចង់ឲ្យបានជួបជុំគ្រួសារនោះធ្វើមិនបានសម្រេច, កូនលោកអ្នកអាចគេស្នើសុំយកធ្វើកូនចិញ្ចឹមបាន។

មូលហេតុជាក់លាក់ដែលលោកអ្នកត្រូវមកតុលាការ គឺមានបញ្ជាក់នៅក្នុងបណ្តឹងទាមទារ ហើយនិងនៅក្នុងលិខិតផ្សេងៗ ដែលលោកអ្នកបានទទួលនោះ។

**សូមអានលិខិតបណ្តឹងទាមទារនេះឲ្យបានម៉ត់ចត់។**



**6. តើតុលាការរៀបចំធ្វើគំរោងអចិន្ត្រៃយ៍ឲ្យកូនខ្ញុំដោយរបៀបណា ?**




a. បើសិនជាតុលាការសម្រេចថា កូននោះគេមិនប្រគល់មកឲ្យលោកអ្នកវិញទេហើយគំរោងផ្សេងទៀតតម្រូវឲ្យមានសំរាប់ក្មេងនោះ តុលាការ**ត្រូវតែ**រៀបចំដាក់សវនាការក្នុងកំឡុងពេល បួនខែ ដើម្បីធ្វើការសម្រេចអ្វីដែលគួរកើតមានឡើងដល់កូនលោកអ្នក។

b. នៅពេលសវនាការនោះ តុលាការមានតែបីជំរើសប៉ុណ្ណោះ ដូចលំដាប់គោលការតទៅនេះ :

(1) បញ្ចប់សិទ្ធិជាឪពុកម្តាយរបស់លោកអ្នក ហើយចេញបទបញ្ជាដាក់កូននោះឲ្យគេសុំយកទៅធ្វើជាកូនចិញ្ចឹម ("ការបញ្ចប់សិទ្ធិឪពុកម្តាយរបស់លោកអ្នក" មានន័យស្របច្បាប់ថា លោកអ្នកអស់មានសិទ្ធិធ្វើជាឪពុកម្តាយរបស់កូននោះទៀតហើយ);

(2) ចាត់តាំងដាក់ឲ្យមានអាណាព្យាបាលពេញច្បាប់ឲ្យកូននោះ; ឬ

(3) ដាក់កូននោះឲ្យរស់នៅក្នុងមន្ទីរចិញ្ចឹមបីបាច់ថែរក្សាយូរអង្វែង។

បើសិនជាមានញាតិសន្តានស្នើសុំយកកូននោះធ្វើជាកូនចិញ្ចឹម លោកអ្នកក្លាយជាឪពុកម្តាយចិញ្ចឹម ហើយកូននោះយល់ព្រមដល់កិច្ចសន្យាមុនការស្នើសុំយកធ្វើជាកូនចិញ្ចឹមនេះរវាងលោក អ្នកនិងកូនលោកអ្នក។ មេធាវីរបស់លោកអ្នកអាចពន្យល់ពី "កិច្ចព្រមព្រៀងស្នើសុំកូនចិញ្ចឹមជាសាច់ញាតិ" (Kinship Adoption Agreement) នេះដល់លោកអ្នកបើសិនជាការស្នើសុំកូននេះមកធ្វើជាកូនចិញ្ចឹមដោយញាតិសន្តានជាគំរោងអចិន្ត្រៃយ៍។



c. បើកូនលោកអ្នកមាន**អាយុក្រោមបីឆ្នាំ** នៅពេលគេបានដកយកកូនចេញពីលោកអ្នកជាលើកដំបូង ហើយលោកអ្នកមិនបានមកចូលរួមនៅក្នុងបទបញ្ជាតុលាការគ្រប់ពេលវេលាទេ ឬបើសិនជាគេមិនដែលបានទាក់ទងមកលោកអ្នក ឬលោកអ្នកមិនដែលបានមកមើលសួរសុខទុក្ខកូនជាងប្រាំមួយខែកន្លង ហើយ, តុលាការអាចបញ្ចប់សេវាបំរើនោះ។ បើសិនជាបងប្អូនប្រុស ឬស្រីនៃកូននោះមានអាយុក្រោមបីឆ្នាំគេបានដកយកចេញពីលោកអ្នកផងដែរកិច្ចបំរើក៏គេបញ្ចប់ដល់ក្មេងនោះផងទៀត។

d. បើសិនជាកូនលោកអ្នកមាន**អាយុលើសពីបីឆ្នាំ** ហើយគេមិនប្រគល់កូននោះឲ្យលោកអ្នកប្រាំមួយខែក្រោយមក តុលាការអាចចេញបទបញ្ជាឲ្យសេវាបំរើបន្តសំរាប់ប្រាំមួយខែទៀត។



e. សេវាបំរើដើម្បីឲ្យលោកអ្នកបានជួបជុំកូនវិញនឹងបញ្ចប់ក្នុងរយៈពេល 12 ខែក្រោយមក លុះណាតុលាការបានសម្រេចថា មាន***ភាពអាចកើតមានឡើងច្រើនគួរសម***ដែលធ្វើឲ្យកូនលោកអ្នកអាចវិលត្រឡប់ទៅរស់នៅជាមួយលោកអ្នកវិញនៅចុង 18 ខែ ចាប់ពីពេលប៉ូលីស ឬអ្នកទទួលខុសត្រូវសង្គមបានដកយកកូននោះចេញពីលោកអ្នក។

f. បើសិនជាសេវាបំរើនោះបានគេបញ្ចប់ តុលាការនឹងធ្វើការរៀបចំសវនាការមួយដើម្បីធ្វើគំរោងអចិន្ត្រៃយ៍សំរាប់កូនលោកអ្នក។

*ដើម្បីឲ្យតុលាការសម្រេចចិត្តប្រគល់កូនឲ្យមកលោកអ្នកវិញ លោកអ្នកត្រូវតែធ្វើតាមបទបញ្ជាតុលាការដោយគ្មានរារាំងពន្យាពេលវេលាឡើយ។*

*ពីព្រោះ បើសិនជាតុលាការចេញបទបញ្ជាឲ្យមានសវនាការសំរាប់គំរោងអចិន្ត្រៃយ៍, កូននោះគេនឹងមិនប្រគល់ឲ្យមកលោកអ្នកវិញទេ ហើយក៏គ្មានការផ្តល់ជំនួយពីអ្នកទទួលខុសត្រូវសង្គម ឬក៏តុលាការជួយឲ្យលោកអ្នកបានជួបជុំកូនវិញបានដែរ។*



## 1. តើខ្ញុំត្រូវមានមេធាវីឬទេ ?



លោកអ្នកមានសិទ្ធរកមេធាវីដើម្បីជួយធ្វើជាតំណាងការពារក្តី របស់លោកអ្នកនៅក្នុងតុលាការកាត់ក្តី, ហើយសវនាការដំបូងរបស់លោកអ្នកប្រហែលជាមានការពន្យាពេលយ៉ាងខ្លី ដូច្នេះ លោកអ្នកប្រហែលជាអាចរកមេធាវីបាន។ បើសិនជាលោកអ្នកមិនអាចមានសមត្ថភាពរកជួលមេធាវីបានទេ តុលាការប្រហែលជាផ្តល់មេធាវីឲ្យលោកអ្នក។ លោកអ្នកប្រហែលជាត្រូវបង់សងថ្លៃមេធាវីមកតុលាការវិញតាមសមត្ថភាពលោកអ្នកអាចធ្វើទៅបាន។

## 2. តើមានអ្នកណាទៀតដែលត្រូវមានមេធាវីផង ?

ទីប្រឹក្សាច្បាប់ខោនធីប្រហែលជាធ្វើជាតំណាងការពារឲ្យអ្នកទទួលខុសត្រូវសង្គម ហើយតុលាការប្រហែលជាចាត់តាំងមេធាវីធ្វើជាតំណាងការពារក្តីឲ្យកូនលោកអ្នក។ ភារៈកិច្ចរបស់មេធាវី គឺធ្វើជាតំណាងការពារផលប្រយោជន៍ឲ្យកូនលោកអ្នក។ តុលាការចាត់តាំងតំណាងការពារសិទ្ធិពិសេស ហៅថា អ្នកស្ម័គ្រ CASA (កាសា) ក៏ប្រហែលជាចាត់តាំងធ្វើជាតំណាងការពារកូនលោកអ្នកផងដែរ។

## 3. តើអ្វីនឹងមានកើតឡើងនៅពេលសវនាការដំបូង ?



a. បើសិនជាកូនលោកអ្នកគេបានដកយកចេញពីលោកអ្នក នៅពេលមានសវនាការតុលាការដំបូង ចៅក្រមនឹងសម្រេច បើត្រូវប្រគល់កូននោះទៅឲ្យលោកអ្នកវិញនៅសវនាការលើកក្រោយ ឬតុលាការទុកកូននោះដដែរ។

b. ធ្វើយ៉ាងណាកុំភ្លេចនិយាយប្រាប់អ្នកទទួលខុសត្រូវសង្គម ឬមេធាវីអំពីញាតិសន្តានរបស់កូនលោកអ្នកដែលអាចសមត្ថភាពមើលថែរក្សាកូនលោកអ្នកបានទំរាំដល់ពេលសវនាការ លើកក្រោយ (ឬយូរជាងនេះ) បើសិនជាគេមិនប្រគល់កូនមកឲ្យលោកអ្នកវិញនៅសវនាការដំបូង។

c. នៅក្នុងករណីច្រើន លោកអ្នកនឹងអាចមកលេងសួរសុខទុក្ខជាមួយកូនបាន បើសិនជាកូននោះគេមិនប្រគល់ឲ្យមកលោកអ្នកវិញនៅឡើយ។

**4. តើអ្វីនឹងកើតមានឡើងបន្ទាប់មក ?**

a. លោកអ្នកមានសិទ្ធសុំឲ្យមានការជំនុំជំរះក្តីដែលមានចៅក្រម នឹងសម្រេចមើលលើគោលសេចក្តីក្នុងបណ្តឹងទាមទារនោះពិតប្រាកដត្រឹមត្រូវមែនទេ។

b. បើសិនជាមានការជំនុះជំរះក្តី គេនឹងដាក់ខែថ្ងៃឆ្នាំសំរាប់ការជំនុំជំរះក្តីនោះ។

c. ទោះជាកូននោះនៅជាមួយលោកអ្នក ឬក៏អត់ បើសិនជាលោកអ្នកសារភាពថាគោលសេចក្តីទាំងអស់ ឬមួយផ្នែកណាមួយក្នុងបទបណ្តឹងទាមទារពិតប្រាកដត្រឹមត្រូវ ឬអនុញ្ញាតឲ្យចៅក្រមធ្វើការសម្រេចចិត្ត យោងទៅលើរបាយការណ៍ដែលមានបង្ហាញ និងមិនមានការជំនុំជំរះក្តីទាំងនោះ។

អ្នកទទួលខុសត្រូវសង្គមនឹងធ្វើការរៀបចំនូវរបាយការណ៍ឲ្យតុលាការ ដែលយោងទៅលើការស៊ើបអង្កេតដែលនឹងរួមបញ្ចូលការពិភាក្សាជាមួយលោកអ្នក ហើយនិងជាមួយអ្នកដទៃទៀត។ របាយការណ៍ និងការចូលរួមមានការណែនាំព្រានប្រដៅកូនលោកអ្នកត្រូវទៅរស់នៅទីកន្លែងណានៅក្នុងកំឡុងពេលប្រាំមួយខែខាងមុខ (នៅពេលណាសវនាការ តុលាការកោះហៅទៀត) ហើយលោកអ្នកនិងអ្នកដទៃអាច ធ្វើអ្វីដែលជួយដល់ការដោះស្រាយបញ្ហាដែលនាំឲ្យលោកអ្នក និងកូនមកឡើងតុលាការកាត់ក្តីនោះ។

បើសិនជាចៅក្រមបានគិតសម្រេចថា គោលសេចក្តីក្នុងបណ្តឹងទាមទារនោះត្រឹមត្រូវមែន ចៅក្រមប្រហែលជាអាចសំរេចយកកូនលោកអ្នកជាបន្ទុករបស់តុលាការ មានន័យថាការត្រួតមើលខុសត្រូវរបស់លោកអ្នកនឹងមានកម្រិត ហើយកូននោះគេប្រហែលជាអាចដកយកចេញលោកអ្នកបាន។

នឹងមានគំរោងករណីដែលនឹងធ្វើឡើងដោយលោកអ្នក ហើយនិងអ្នកទទួលសុខត្រូវសង្គម; គំរោងនេះនឹងប្រគល់ឲ្យទៅតុលាការ។ តុលាការនឹងប្រហែលជាអាចចេញបទបញ្ជាគំរោងករណីទាំងមូល ឬមួយផ្នែកណាមួយយកមកវិនិច្ឆ័យ។ គំរោងករណីប្រហែលជារួមបញ្ចូលទាំងរបស់របរដូចមានតទៅនេះ :



a. ថ្នាក់ណែនាំដល់ឪពុកម្តាយ
b. ការណែនាំព្រានប្រដៅផ្ទាល់ម្នាក់ៗ
c. ការណែនាំទូន្មានដល់ក្រុមគ្រួសារ
d. ការមើលព្យាបាលលើការញៀនសុរានិងគ្រឿងញៀនផ្សេងៗ



e. កម្មវិធីនិងថ្នាក់បង្ហាត់បង្រៀនពិសេស
f. ការមកមើលសួរសុខទុក្ខកូន



បើសិនជាគេដកយកកូនចេញពីលោកអ្នក ហើយមានបទបញ្ជាគំរោងករណី អ្នកទទួលខុសត្រូវសង្គមនឹងតម្រូវឲ្យមានការបូកបញ្ចូលក្នុងគំរោងករណី : (1) សេវាកិច្ចបំរើជួយដល់លោក អ្នកបានជួបជុំជាមួយកូនវិញ ហើយ (2) សេវាកិច្ចបំរើជួយសំរេចដំណើរការច្បាប់ទម្លាប់សំរាប់កូនរបស់លោកអ្នក បើការជួបជុំក្រុមគ្រួសារវិញនោះធ្វើមិនបានសម្រេច។ ព្រឹត្តិការណ៍ច្បាប់ រួមទាំងការសុំយកកូនទៅចិញ្ចឹមបីបាច់ថែរក្សា ឬចាត់តាំងឲ្យមានអាណាព្យាបាលពេញច្បាប់ណាមួយ។

បើសិន, គ្រប់ពេលវេលាក្រោយពីគេបានដកយកកូនចេញពីលោកអ្នក, លោកអ្នកពុំមានចិត្តចង់ជួបជុំជាមួយកូនវិញទេ លោកអ្នកអាចពិភាក្សាជាមួយអ្នកទទួលខុសត្រូវសង្គម។ លោកអ្នកក៏គួរនិយាយពិភាក្សាជាមួយមេធាវីលោកអ្នកផងដែរ, ដែលជាអ្នកអាចពន្យល់ពីសិទ្ធិរបស់លោកអ្នកមានចំពោះការ (1) លើកលែងតែសេវាបំរើលើការឲ្យបានជួបជុំគ្នាវិញ, (2) ប្រគល់ សិទ្ធិជាឪពុកម្តាយឲ្យគេ ហើយ (3) ការជួយក្នុងការបង្កើតគំរោងអចិន្ត្រៃយ៍សំរាប់កូន។

**5. តើខ្ញុំត្រូវធ្វើយ៉ាងណាបន្ទាប់មក ?**

a. អ្នកទទួលខុសត្រូវសង្គមនិងអ្នកដទៃនឹងតម្រូវឲ្យជួយដល់លោកអ្នកក្នុងការស្នើសុំកិច្ចបំរើមានចុះក្នុងគំរោងករណីរបស់លោកអ្នក។

***វាជាការសំខាន់ណាស់ដែលលោកអ្នកចាប់ផ្តើមធ្វើគំរោងករណីទាន់ពេលវេលាអាចធ្វើទៅបាន។ ការធ្វើតាមគំរោងករណីនៅក្នុង រយៈពេលតម្រូវមានកំណត់នោះជាកន្លិះជួយដល់ការអាចវិល ត្រឡប់កូនមកឲ្យលោកអ្នកវិញបាន។***



b. តុលាការនឹងពិនិត្យមើលករណីរបស់លោកអ្នកឡើងវិញ យ៉ាងតិចក្នុងរយៈពេលប្រាំមួយខែម្តង។ នៅពេលសវនាការ ដំបូងពិនិត្យមើលឡើងវិញ តុលាការនឹងគិតមើលបើកូនលោកអ្នកជាបន្ទុករបស់តុលាការនោះ នៅតែតម្រូវឲ្យមាន ហើយបើសិនជាគេបានដកយកកូនចេញពីលោកអ្នកប្រហែលជាអាចវិលត្រឡប់ទៅផ្ទះវិញបាន។